ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ........៨១៥.......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពីការផ្តល់ឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយ
## ការដាក់លិខិតប្រកាសពន្ធប្រចាំខែ ជា Soft Copies

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស សូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ដែលមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រចាំខែជ្រាបថា ការដាក់លិខិតប្រកាសពន្ធ ប្រចាំខែតម្រូវឱ្យក្រុមហ៊ុនភ្ជាប់មកជាមួយនូវឯកសារឧបសម្ព័ន្ធមួយចំនួនដូចជា ទិន្នានុប្បវត្តិទិញ និង ទិន្នានុប្បវត្តិលក់ (Sales and Purchases Records) តារាងលម្អិតស្តីពីពន្ធលើប្រាក់បៀវត្ស និងពន្ធកាត់ទុក (Detail Schedules on Tax on Salary and Withholding Tax)។ ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាសជា Hard Copies និងចំណេញពេលវេលា សូមលោក-លោកស្រី ភ្ជាប់មកជាមួយនូវឯកសារឧបសម្ព័ន្ធទាំងនេះជា Soft Copies ក្នុងទម្រង់ជា Excel Spread-sheet ហើយសូមបញ្ចូលលេខអត្តសញ្ញាណសារពើពន្ធថ្មី ៩ខ្ទង់ចុងក្រោយ (លេខសុទ្ធដោយមិនលាយតួអក្សរទេ)។ ចំពោះទឹកប្រាក់ក្នុងទិន្នានុប្បវត្តិទិញ និង ទិន្នានុប្បវត្តិលក់ ត្រូវកត់ត្រាជាប្រាក់រៀល (ដោយគ្មានលាយរូបិយវត្ថុផងទៃ)។

ការចេញលេខរៀងវិក្កយបត្រគឺត្រូវចេញពីលេខ ១ ចំពោះវិក្កយបត្រទី១ នៅថ្ងៃទី១ ខែមករា និងចេញរៀងតាមលំដាប់រហូតដល់វិក្កយបត្រចុងក្រោយបំផុត នាពេលបិទម៉ោងអាជីវកម្មនៃថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធ នីមួយៗ ហើយវិក្កយបត្រត្រូវចេញតាមលំដាប់លេខរៀងជាពីរខ្សែគឺ វិក្កយបត្រអាករមួយខ្សែសម្រាប់ការផ្គត់ផ្គង់ឱ្យបុគ្គលជាប់អាករ និងមួយខ្សែទៀតជាវិក្កយបត្រធម្មតាសម្រាប់ការផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់។ រាល់វិក្កយបត្រដែលចាត់ទុកជាមោឃៈដោយប្រការណាមួយត្រូវមានអំណះអំណាងច្បាស់លាស់ ត្រឹមត្រូវ និងត្រូវរក្សាទុកជាឯកសារភស្តុតាង។

ក្នុងករណី លោក-លោកស្រី មានចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យចុះបញ្ជី និងសេវាអ្នកជាប់ពន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខ័ណ្ឌ និងសាខាពន្ធដារខេត្តដែលទាក់ទិន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសពិតជាយកចិត្តទុកដាក់អញ្ជើញមកដាក់លិខិតប្រកាសតាមទម្រង់កំណត់ និងបង់ពន្ធតាមច្បាប់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន ពន្ធដារ

គង់ វិបុល